ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

# សាលាបឋមសិក្សា សោថហ្វក (Southwark)

*"ទោះជាភាសាអ្វីក៏ដោយ ការញញឹមគឺដូចគ្នាទាំងអស់"*

**Mr. Andrew Lukov**, *នាយកសាលា*

1835 South 9th Street Philadelphia, PA 19148
ទូរស័ព្ទ៖ ២១៥-៩៥២-៨៦០៦ ទូរសារ៖ ២១៥-៩៥២-៨៦៧០

**<u>ព័ត៌មានសំខាន់ៗរបស់សាលាបឋមសិក្សា សោថហ្វក</u>**

**ការទទួលខុសត្រូវរបស់ មាតាបិតា/អាណាព្យាបាល**

- មើលឡើងវិញនូវ វិន័យ និងបទបញ្ជា របស់សាលា សោថហ្វក ជាមួយកូន។
- ជូនដំណឹងដល់សាលា សោថហ្វក នៅពេលមានការផ្លាស់ប្តូរ អាស័យដ្ឋាន ឬលេខទូរស័ព្ទ។
- ផ្តល់ឲ្យសាលា សោថហ្វក នូវព័ត៌មានថ្មីៗ សម្រាប់ទាក់ទងពេលមានអាសន្ន។
- ធ្វើយ៉ាងណាឲ្យកូនទៅរៀនទាន់ម៉ោងជារៀងរាល់ថ្ងៃ។
- បើទៅទទួលកូនពីរៀនរាល់ថ្ងៃ ធ្វើយ៉ាងណាទៅយកឲ្យទាន់ម៉ោងជារៀងរាល់ថ្ងៃ។
- នៅពេលអវត្តមាន សូមផ្តល់លិខិតបញ្ជាក់ពីមូលហេតុនៃអវត្តមាន ក្នុងកំឡុងពេល៣ថ្ងៃ នៅពេលកូនរបស់លោកអ្នកត្រឡប់មករៀនវិញ។
- ធ្វើយ៉ាងណាឲ្យកូនស្លៀកពាក់ឯកសណ្ឋានសាលាឲ្យបានត្រឹមត្រូវ។
- ធ្វើយ៉ាងណាឲ្យកូនយក សៀវភៅ និងសម្ភារៈសិក្សា ទៅ និងមកពី សាលាជារៀងរាល់ថ្ងៃ។
- ចូលរួមក្នុងអង្គប្រជុំចែករបាយការណ៍ពិន្ទុ និងកម្មវិធីពិសេសៗ។
- ធ្វើយ៉ាងណាឲ្យកូនធ្វើកិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ ឲ្យបានរួចរាល់ ហើយពិនិត្យមើលរាល់ថ្ងៃ ក្រែងមាន កំណត់សម្គាល់ ឬ យោបល់ពីគ្រូ។

**ច្បាប់សម្រាប់ទូរស័ព្ទដៃ**

- បើគេឃើញសិស្សណាប្រើទូរស័ព្ទដៃ គេនឹងដកហូតទូរស័ព្ទដៃរបស់សិស្សនោះ។
- បទល្មើសលើកទី១៖ គេនឹងទុកទូរស័ព្ទរហូតដល់ពេលចេញពីរៀន ហើយប្រគល់ឲ្យសិស្សវិញ។
- បទល្មើសលើកទី២៖ នាយកសាលានឹងទុកទូរស័ព្ទ ហើយអាចប្រគល់ឲ្យទៅតែ មាតាបិតា/អាណាព្យាបាល តែប៉ុណ្ណោះ។
- បទល្មើសលើកទី៣៖ ការអនុវត្តន៍តាមកិច្ចព្រមព្រៀងនៃទូរស័ព្ទដៃរបស់សាលា សោថហ្វក។

**អ្នកស្ម័គ្រចិត្ត**

- សាលា សោថហ្វក ស្វាគមន៍ និងជំរុញឲ្យសមាជិកសហគមន៍ស្ម័គ្រចិត្តចូលរួម។
- អ្នកស្ម័គ្រចិត្តត្រូវការលិខិតបញ្ជាក់ពីប្រវត្តិរូបល្អ។
- នាយកសាលាជាអ្នកចាត់តាំងកិច្ចការឲ្យធ្វើ។

**ដំណើរកំសាន្តនៃការសិក្សារបស់សាលា**

- មាតាបិតាត្រូវចុះហត្ថលេខាលើលិខិតយល់ព្រម។
- គេមិនទទួលស្គាល់ការយល់ព្រមតាមទូរស័ព្ទ ឬតាមរយៈការផ្ញើសារតាមទូរស័ព្ទ នោះទេ។
- គ្មានសិស្សណាម្នាក់អាចចូលរួមក្នុងដំណើរកំសាន្តរបស់ថ្នាក់ ដោយគ្មានការចុះហត្ថលេខាលើលិខិតអនុញ្ញាតបានទេ។
- អ្នកមើលខុសត្រូវលើក្មេងមិនអាចដឹកក្មេងក្នុងរថយន្តរបស់គាត់បានទេ។
- គេមិនអនុញ្ញាតឲ្យសិស្សណាដែលមិនមែនជាសិស្សសាលា សោថហ្វក ចូលរួមក្នុងការធ្វើដំណើរកំសាន្តនៃការសិក្សា ទេ។

**ពេលមកកាន់សាលា**

- មាតាបិតាត្រូវទទួលការអនុញ្ញាតពី ការិយាល័យរបស់សាលា។
- គេមិនអនុញ្ញាតឲ្យមាតាបិតាឆ្ពោះទៅកាន់ថ្នាក់រៀនតែម្តងនោះទេ។
- នៅពេលមកកាន់សាលា មាតាបិតាត្រូវចុះហត្ថលេខា ហើយពាក់ស្លាកសម្គាល់អ្នកដែលមកកាន់សាលា។
- គេមិនអនុញ្ញាតឲ្យមាតាបិតាណាម្នាក់ទៅជួបកូនអ្នកដទៃនោះទេ ទោះជាមានមូលហេតុអ្វីក៏ដោយ។
- បើសិនជាលោកអ្នកមានការបារម្ភចំពោះកូនអ្នកដទៃ សូមជម្រាបទៅបុគ្គលិករបស់សាលា សោថហ្វក។

**រូបថត**

- គេថតរូបសិស្សានុសិស្សពីដើមឆ្នាំដល់ចុងឆ្នាំ។
- មាតាបិតាដែលមិនចង់ឲ្យគេថតរូបកូន ត្រូវជម្រាបទៅនាយកសាលាតាមរយៈការសរសេរជាលាយលក្ខណ៍អក្សរ។

## <u>ការបម្រើផ្សេងៗនៅសាលាបឋមសិក្សា សោថហ្វក</u>

**ការបម្រើផ្នែក សុខភាព និងវេជ្ជសាស្ត្រ**

- មានគិលានុដ្ឋាកម្នាក់ដែលធ្វើការ២ថ្ងៃ ក្នុងមួយសប្តាហ៍។
- សិស្សទាំងអស់ទទួលការពិនិត្យ ត្រចៀក និងភ្នែក។
- គិលានុដ្ឋាកមិនសូវមានពេលច្រើនសម្រាប់ការព្យាបាលនៅពេលមានអាសន្នទេ។
- ការជួយឲ្យថ្នាំសម្រាប់រយៈពេលខ្លី អាចឲ្យបានបើសិនជាមានលិខិតពីមាតាបិតា ហើយថ្នាំនោះត្រូវដាក់នៅក្នុងដបមានបិតស្លាកវេជ្ជបញ្ជា។
- ការជួយឲ្យថ្នាំសម្រាប់រយៈពេលយូរ អាចឲ្យបានបើសិនជាមានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរត្រឹមត្រូវពីវេជ្ជបណ្ឌិត។
- សិស្សានុសិស្សមិនអាចយកថ្នាំពេទ្យមកសាលាបានទេ។

**ការបម្រើផ្នែកផ្តល់ឱវាទ**

- អ្នកផ្តល់ឱវាទរបស់សាលា ផ្តល់ឱវាទដល់សិស្ស ម្នាក់ៗ ឬជាក្រុម អំពី រឿងផ្ទាល់ខ្លួន បញ្ហាក្នុងសង្គម ឬបញ្ហានៅសាលា។
- រឿង សម្លុតធ្វើបាប/យាយី ត្រូវរាយការណ៍ទៅ អ្នកផ្តល់ឱវាទរបស់សាលា។
- អ្នកផ្តល់ឱវាទរបស់សាលាអង្កេតរឿង សម្លុតធ្វើបាប/យាយី រួចហើយផ្តល់ឱវាទដល់ ជនរងគ្រោះ និងជនប្រព្រឹត្តបទល្មើស។
- អ្នកផ្តល់ឱវាទរបស់សាលាដោះស្រាយបញ្ហាភ្លាមៗ រវាងសិស្សនឹងសិស្ស ហើយសហការជាមួយគ្រូ មាតាបិតា និងដៃគូនៅក្នុងសហគមន៍។
- អ្នកផ្តល់ឱវាទ ក៏តាមដានវត្តមានអវត្តមានរបស់សិស្សដែរ ហើយលោកអ្នកអាចទាក់ទងបានបើមានការបារម្ភអ្វីអំពីវត្តមានអវត្តមាន។
- អ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា មានពេលជួយក្រុមគ្រួសារនៅថ្ងៃខុសៗគ្នា។
- នៅពេលណាលោកអ្នកមានការបារម្ភអំពីកូន សូមទាក់ទងមកបុគ្គលិកផ្នែកផ្តល់ឱវាទ។ អ្នកផ្តល់ឱវាទ និងអ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា នៅទីនេះដើម្បីជួយ ក្រុមគ្រួសារ និងសិស្សានុសិស្ស របស់យើង។

**ការបម្រើផ្នែកបកប្រែភាសា**

- សមាជិកបុគ្គលិកទាំងអស់ អាចប្រើការបកប្រែភាសាតាមទូរស័ព្ទ តាមរយៈក្រុមហ៊ុន ប៉ាស៊ីហ្វិក អ៊ិនធ័រព្រីទ័រ (Pacific Interpreters)។
- មានអ្នកបកប្រែជាង២០០ភាសា អាចជួយបកប្រែបានភ្លាមៗ។
- អាចប្រើសេវានេះនៅពេលប្រជុំទល់មុខគ្នា តាមរយៈនៃការបើកសម្លេងទូរស័ព្ទឲ្យឮ ឬតាមរយៈនៃការប្រើទូរស័ព្ទបីខ្សែបញ្ចូលគ្នា។

**អាហារពេលព្រឹក/អាហារថ្ងៃត្រង់**

- មានអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ ដែលមានជីវជាតិ សម្រាប់សិស្សទាំងអស់ ដោយឥតគិតថ្លៃ។
- អាហារពេលព្រឹក ញ៉ាំនៅក្នុងសាលញ៉ាំអាហារពេលថ្ងៃត្រង់ នៅម៉ោង ៨:០០ ព្រឹក។
- ដើម្បីធ្វើឲ្យអាហារពេលថ្ងៃត្រង់មានបរិយាកាសរីករាយដល់សិស្សទាំងអស់ សិស្សានុសិស្សត្រូវ៖
    - អង្គុយនៅតុដែលគេបានចាត់ឲ្យអង្គុយ។
    - អង្គុយនៅមួយកន្លែងរហូតដល់ពេលគេហៅឲ្យទៅយកអាហារថ្ងៃត្រង់
    - រៀបចំតុបាយឲ្យបានស្អាតបាត មុនពេលចាកចេញពីតុ។
    - ចោលកាកសំណល់ទាំងអស់ក្នុងធុងសំរាម។
    - ត្រូវនៅក្នុងសាលញ៉ាំអាហារថ្ងៃត្រង់ ក្នុងកំឡុងពេលសម្រាប់ញ៉ាំអាហារថ្ងៃត្រង់។
    - ចាំរហូតដល់គេប្រាប់ឲ្យចេញ ពីតុនីមួយៗ។
    - គេមិនអនុញ្ញាតឲ្យយក វិទ្យុ គ្រឿងសម្រាប់ពាក់ត្រចៀកស្ដាប់ គេជ័រ ទូរស័ព្ទដៃ ល្បែងលេងអេឡិចត្រូនិច ឬប្រដាប់លេង មកក្នុងសាលញ៉ាំអាហារថ្ងៃត្រង់ ឬទៅកន្លែងណាមួយនៅក្នុងអាគារ ទេ។